ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៣ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែ ធ្នូ ឆ្នាំ ២០១០



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពី វិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពី ធានារ៉ាប់រង | ៣ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការគ្រប់គ្រងបុរី | ៤ |
| ៤- | កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម | ៥ |
| ៥- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០ | ៦ |
| ៦- | សកម្មភាពដ៏ទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១២ |
| ៧- | របាយការណ៍សង្ខេបស្តីពី កិច្ចប្រជុំនៅរដ្ឋបាលជលផល | ១៧ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# វិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់



កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ជាសហប្រធានអង្គប្រជុំ **ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី វិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសុខាភិបាល សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល បានសហការជាមួយក្រសួងនានា ជាសមាជិកគណៈកម្មាធិការអន្តរក្រសួង ដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ បានខិតខំរៀបចំតាក់តែងសេចក្តីព្រាងអនុក្រឹត្យស្តីពី វិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ក្នុងគោលបំណងសំខាន់ៗ ដូចខាង ក្រោម៖

-ចូលរួមចំណែកក្នុងការការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ

-បង្កើនប្រសិទ្ធភាពត្រួតពិនិត្យលើការផ្សព្វផ្សាយផលិតផលថ្នាំជក់

-កាត់បន្ថយការប្រើប្រាស់ផលិតផល់ថ្នាំជក់

-ទប់ស្កាត់រាល់មធ្យោបាយផ្សព្វផ្សាយដែលទាក់ទាញអតិថិជនឱ្យប្រើប្រាស់ផលិតផលថ្នាំជក់

-កាត់បន្ថយផលប៉ះពាល់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ទៅលើសុខភាព បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

នៅលើពិភពលោកទាំងមូល ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ការប្រើប្រាស់ផលិតផលថ្នាំជក់កាន់តែរីករាលដាល។ ការប្រើប្រាស់ផលិតផលថ្នាំជក់នេះ មិនត្រឹមតែមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ និងអ្នកស្រូបផ្សែងបារីពីអ្នកជក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងបរិស្ថានផងដែរ។ ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា អត្រាអ្នកជក់បារី ក្នុងចំណោមមនុស្សពេញវ័យមានកម្រិតខ្ពស់។ តាមការស្រាវជ្រាវនៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា នៅចន្លោះឆ្នាំ២០០៥-២០០៦ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបង្ហាញថា ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់នាពេលថ្មីៗនេះគឺ បុរសមាន ៤៩% និងស្ត្រីមាន ២០.៥%។

ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ជាក់លាក់រួមមាន ការជក់បារី ការបុកថ្នាំជក់ដោយប្រើខ្សៀ។ ចំពោះការជក់បារី បុរសមាន ៤៨% និងស្ត្រីមាន ៣.៦% ចំពោះការបុកថ្នាំជក់ បុរសមាន ១% និងស្ត្រីមាន ១៧%។ ការប្រើថ្នាំជក់លាយឡំគ្នាទាំងបុកថ្នាំជក់ បុរសមាន ០.៣% និងស្ត្រីមាន ០.៤%។ ម្យ៉ាងទៀត ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ គឺមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ពិសេសយុវវ័យ។ ការស្រាវជ្រាវបានបង្ហាញថា បើគ្មានវិធានការហាមឃាត់ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ទេ អត្រានៃការប្រើប្រាស់ថ្នាំជក់ថយចុះតែ ១%ប៉ុណ្ណោះ តែបើមានវិធានការការហាមឃាត់ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ទាំងស្រុង អត្រានៃការប្រើប្រាស់ថ្នាំជក់ ថយចុះរហូតដល់ ៨% ក្នុងរយៈពេល១០ឆ្នាំ។

ទោះបីជាពុំមានទិន្នន័យច្បាស់លាស់ពីទំហំនៃការផ្សព្វផ្សាយពាណិជ្ជកម្ម ការលើកកម្ពស់និងការឧបត្ថម្ភផលិតផលថ្នាំជក់ក៏ដោយ គេសង្កេតឃើញថា ការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈសម្ភារៈបោះពុម្ព និងផ្ទាំងប៉ាណូនៅមានវត្តមានជាច្រើននៅតាមទីសាធារណៈ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួល ខ្លឹមសារ ទម្រង់ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្ដីព្រាងនេះកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងឯកសារនេះទាំងស្រុង៕




(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុស្ដីពី សេចក្ដីព្រាងអនុក្រឹត្យស្ដីពីវិធានការចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់។

# សេចក្តីព្រាងច្បាប់ស្តីពី ការធានារ៉ាប់រង



កាលពីថ្ងៃទី៨ ទី១៦ ទី២២ ទី២៨ និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីការធានារ៉ាប់រង** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំឭកថា សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការធានារ៉ាប់រង បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេសកាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០។ អង្គប្រជុំនៅពេលនោះបានស្នើឲ្យសាមីក្រសួងរៀបចំជាថ្មីនូវសេចក្តីព្រាងច្បាប់ស្តីពី ការធានារ៉ាប់រង ពីព្រោះខ្លឹមសារនៃការធ្វើវិសោធនកម្មនេះ លើសពីមាត្រាដែលមានចែងនៅក្នុងច្បាប់ចាស់ទៀត។ សាមីក្រសួងបានទទួលយកការស្នើនេះ ហើយបានរៀបចំចេញជាសេចក្តីព្រាងថ្មីច្បាប់ស្តីពី ការធានារ៉ាប់រង ជំនួសច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការធានារ៉ាប់រង។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងថ្មីនេះ ហើយបានសម្រេចកែសម្រួល ខ្លឹមសារ ទម្រង់ពាក្យពេចន៍ ឃ្លាប្រយោគ និងព្យួរទុកបញ្ហាកាតព្វកិច្ចធានារ៉ាប់រងរបស់ម្ចាស់យានយន្ត។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅមាត្រា ៣៣ថ្មី៕





## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការគ្រប់គ្រងបុរី

កាលពីថ្ងៃទី១៦ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **លឹម អេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការគ្រប់គ្រងបុរី ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក និងអគ្គលេខាធិការរងនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



ដោយអនុលោមតាមការវិវត្តរីកចម្រើនរបស់ប្រទេសជាតិ និងការកើនឡើងលើវិស័យដីធ្លី និងទីផ្សារដីធ្លី ជាពិសេសការអភិវឌ្ឍលើវិស័យសំណង់អគារខ្ពស់ៗក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការគ្រប់គ្រងបុរី ដើម្បីសម្រួលដល់ធុរជន និង វិនិយោគិនក្នុងនិងក្រៅប្រទេស ដែលមកបណ្តាក់ទុនរកស៊ីនៅព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងអនុក្រឹត្យនេះមានគោលបំណងជានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់របស់កម្មសិទ្ធិករនៃដីឡូត៍ និងកម្មសិទ្ធិករនៃដីឡូត៍ដែលមានសំណង់លំនៅឋាន និងសំណង់ផ្សេងទៀត ព្រមទាំងកម្មសិទ្ធិករនៃចំណែកឯកជន នៃអគារសហកម្មសិទ្ធិដែលមាននៅក្នុងបរិវេណនៃបុរី ព្រមទាំងសម្រួលដល់កម្មសិទ្ធិករនៃលំនៅឋាន និងសំណង់ផ្សេងទៀតក្នុងបរិវេណនៃបុរី ក្នុងការលក់ ការដូរ ការធ្វើអំណោយ ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំនូវកម្មសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់។ ទន្ទឹមនេះសេចក្តីព្រាងអនុក្រឹត្យខាងលើនេះ ក៏សំដៅធានាការពារនូវលម្អសាធារណៈនានា និងរក្សាសោភណភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងបរិវេណនៃបុរីផងដែរ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះកាន់តែសុក្រឹត។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងឯកសារនេះនៅជំពូកទី៥៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុស្តីពី សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការគ្រប់គ្រងបុរី។

## កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

កាលពីថ្ងៃទី២ ទី៧ ទី៩ ទី១៥ ទី២១ និងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:00 នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ឯកឧត្តម **ឃួឃាន ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងលោកជំទាវ **លី វួចឡេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម សមាជិក និង អគ្គលេខាធិការរង នៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការ គណៈរដ្ឋមន្ត្រី។

អង្គប្រជុំជំនាញបច្ចេកទេសបានបន្តពិនិត្យពិភាក្សា លើសេចក្តីព្រាងច្បាប់នេះចាប់ពីមាត្រា៨៥។ ការពិនិត្យពិភាក្សាបានប្រព្រឹត្តទៅដោយប្រុងប្រយ័ត្នលើខ្លឹមសារនីមួយៗ ដូចលើកៗមុនដែរ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍និងឃ្លាឃ្លោងមួយចំនួន ដើម្បីឱ្យអ្នក អានយល់បាននូវខ្លឹមសារនៃមាត្រានីមួយៗ ជៀសវាងការ បកស្រាយផ្សេង។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាជា បណ្តោះអាសន្ននៅជំពូកទី១១៕







អង្គប្រជុំជំនាញបច្ចេកទេសបានបន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចាប់ពីមាត្រា៨៥។ ការពិនិត្យពិភាក្សាបានប្រព្រឹត្តទៅដោយប្រុងប្រយ័ត្នលើខ្លឹមសារនីមួយៗដូចលើកៗមុនដែរ ហើយបានសម្រេចកែសម្រួល ខ្លឹមសារ ទម្រង់ ពាក្យពេចន៍ និងឃ្លាឃ្លោងមួយចំនួន ដើម្បីឱ្យអ្នកអានយល់បាននូវខ្លឹមសារនៃមាត្រានីមួយៗ ជៀសវាងការ បកស្រាយផ្សេង។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាជា បណ្តោះអាសន្ននៅជំពូកទី១១៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
# ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០



កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានរៀបចំកិច្ចប្រជុំទូលាយមួយ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០ ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

- *សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ក្នុងខែវិច្ឆិកាឆ្នាំ២០១០នេះ ថយចុះ ១% បើធៀបនឹងខែតុលា ប៉ុន្តែកើនឡើង ៣.២% ក្នុងរយៈពេល១២ខែ។* ទៅលើការថយចុះនៃសន្ទស្សន៍ថ្លៃសរុបដែលមិនធ្លាប់មាននាឆ្នាំ២០១០នេះ ក្រុមម្ហូបអាហាររួមចំណែក ៦២% និងក្រៅពីនោះ ក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀតរួមចំណែក ១១% ការដឹកជញ្ជូន ១៣% និងភោជនីយដ្ឋាន ៨%។
- *ការថយចុះនៃសន្ទស្សន៍ថ្លៃក្នុងខែវិច្ឆិកានេះ ធ្វើឲ្យសន្ទស្សន៍ថ្លៃមធ្យមនៃទំនិញប្រើប្រាស់គ្រប់មុខ កើនឡើងត្រឹមតែ ៤.១% បើប្រៀបធៀបរយៈពេល ១១ខែ ដូចគ្នានៃឆ្នាំ២០០៩។*
- បើពិនិត្យតាមក្រុមទំនិញវិញ ការប្រៀបធៀបខែ(វិច្ឆិកា/តុលា) បង្ហាញបំរែបំរួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ក្រុមដែលមានសន្ទស្សន៍ថ្លៃកើនឡើង (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) | ក្រុមដែលមានសន្ទស្សន៍ថ្លៃថយចុះ (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ▪ សុខាភិបាល: +0.១% (+0.៣%)<br>▪ ទំនិញ និងសេវាកម្មផ្សេងទៀត: +0.៨% (+១១%) | ▪ ម្ហូបអាហារ: –១.៤% ( +៤.១% )<br>▪ ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: –0.៧% ( –0.២%)<br>▪ សំលៀកបំពាក់ និងស្បែកជើង: –0.៥% ( +២.៣%)<br>▪ ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត: –0.៦% ( +២.៧%)<br>▪ ការដឹកជញ្ជូន: –១.១% ( +២.២%)<br>▪ ទូរគមនាគមន៍: –១.0% ( +0.២%)<br>▪ ការកំសាន្ត និងវប្បធម៌: –0.៨% ( –១.៩%)<br>▪ ភោជនីយដ្ឋាន: –១.៣% ( +៣.៤%) |

- អត្រាប្តូរប្រាក់ **៛/បាត** ស្មើនឹង **១៣៥៛/១បាត** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ៤.៣% ធៀបនឹងបាត ប៉ុន្តែចុះថោក ៨% ក្នុងរយៈពេល១២ខែ។
- អត្រាប្តូរប្រាក់ **៛/ដុង** ស្មើនឹង **0.២០៩៛/១ដុង** បើធៀបនឹងខែមុន ប្រាក់រៀលឡើងថ្លៃ ៣.៧% និង ឡើងថ្លៃ ៧.១% ធៀបនឹងដុង ក្នុងរយៈពេល១២ខែ។

## ២) ស្ថានភាពថវិកាជាតិ

- *យោងតាមស្ថិតិដែលឆ្លងកាត់តេនាគារជាតិ **ចំណូលថវិកាជាតិ**ក្នុងខែវិច្ឆិកាឆ្នាំ២០១០នេះ **អនុវត្តបាន**ចំនួន **៥១៨.0 ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៧១% នៃគម្រោង) ក្នុងនោះ **ចំណូលមូលធន ៥៣ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ១១% នៃគម្រោង)* * *និង**ចំណូលចរន្ត ៤៦៥.0 ពាន់លានរៀល** (ជាមធ្យមប្រចាំខែស្មើនឹង ៩៧% នៃគម្រោង)*។
- *បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ**ខែវិច្ឆិកា កើនឡើង ២១% និងកើនឡើង ៣២% ក្នុងរយៈពេល១២ខែ។* **ការកើនឡើង**នេះ គឺបណ្តាលមកពីចំណូលមូលធន *កើនឡើង ២០៥%* និងចំណូលចរន្ត*កើនឡើង ១៣%*។
    - ក្នុងចំណូលចរន្តនាខែវិច្ឆិកា ចំណូលសារពើពន្ធ*កើនឡើង ១២%* និងចំណូលមិនមែនសារពើពន្ធ*កើនឡើង១៩%* ។

| **ក្នុងចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) | **ក្នុងចំណូលមិនមែនសារពើពន្ធ**<br>(ក្នុងវង់ក្រចកៈ បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| ✓ ពន្ធ និងអាករគយ*កើនឡើង ១%* ( +១0%) | ✓ នេសាទ កើនឡើង ១0% ( +៤៦%) |
| ✓ ចំណូលពន្ធដារ*ថយចុះ ១៨%* ( +២.៤%) | ✓ រុក្ខាប្រមាញ់ថយចុះ ៤៤% (មិនមានតួលេខ) |
| ✓ ចំណូលសារពើពន្ធផ្សេងៗ*ថយចុះ ២៦%* ( +៣៩%) | ✓សម្បទានរ៉ែ កើនឡើង ៦៤% ( +១២១%) |
| | ✓ អាកាសចរណ៍ស៊ីវិលកើនឡើង ៦៤% ( –៨២%) |
| | ✓ ផលទុនទេសចរណ៍ កើនឡើង ៥១% ( +២៧%) |
| | ✓ ប្រៃសណីយ៍ និងទូរគមនាគមន៍ ថយចុះ ៥៥% ( –៨៣%) |
| | ✓ អាករស្ថានទូត កើនឡើង ៧៦% ( +៥៥%) |
| | ✓ ត្រួតពិនិត្យគុណភាពផលិតផល ថយចុះ ១២% ( –៣៥%) |
| | ✓ ឯកជនភាវូបនីយកម្ម ថយចុះ ៩១% (មិនមានតួលេខ) |
| | ✓ ការលក់អចលនកម្ម កើនឡើង ៤២៣% ( +១១៨៤0%) |

- ***ចំណាយថវិកាជាតិ*** នៅខែវិច្ឆិកា ឆ្នាំ២០១០នេះ អនុវត្តបាន **៤២៥.១ពាន់លានរៀល** (ជាមធ្យមប្រចាំខែ ស្មើនឹង ៦៨%នៃគម្រោង) ក្នុងនោះ **ចំណាយចរន្ត ៣៤៨.៤ពាន់លានរៀល** (ជាមធ្យមប្រចាំខែៈ ៨៩%នៃគម្រោង) និង**ចំណាយមូលធន ៧៦.៦ពាន់លានរៀល** (ជាមធ្យមប្រចាំខែៈ ៣៥%នៃគម្រោង)។
- *បើធៀបនឹងខែមុន **ចំណាយថវិកាជាតិកើនឡើង** ១៩% និងកើនឡើង ៥១% ក្នុងរយៈពេល១២ខែ។* ការកើនឡើងចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្ត*កើនឡើង ៣៤%* ។ ចំណែកឯចំណាយមូលធន*ថយចុះ២១%* បើធៀបនឹងខែមុន ប៉ុន្តែ*កើនឡើង ៧៣% ក្នុងរយៈពេល១២ខែ*។
- ***តុល្យភាពថវិកាជាតិក្នុងខែវិច្ឆិកានេះមាន**អតិរេកចំនួន ៩៣ពាន់លានរៀល* ។

## ៣) ស្ថានភាពរូបិយវត្ថុ

- ក្នុងខែវិច្ឆិកាឆ្នាំ ២០១០ **រូបិយវត្ថុ** $M_2$ មានចំនួន ***១៩,១០៨ពាន់លានរៀល*** ថយចុះ១.៣% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ២៣% ក្នុងរយៈពេល១២ខែ។ ការថយចុះនៃ $M_2$ នាខែនេះបណ្តាលមកពី ប្រាក់បញ្ញើចរន្ត ថយចុះ 0.៤% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ថយចុះ ១.៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ថយចុះ ១.៧% ។ គួរចាប់អារម្មណ៍ថា រូបិយវត្ថុក្រៅធនាគារនាខែនេះកើនឡើង 0.៨% ធៀបនឹងខែមុន ។

---

* ដោយសារសមាមាត្រតូចនៃការអនុវត្តគំរោងចំណូលមូលធន នាំឲ្យសមមាត្រនៃការអនុវត្តគំរោងចំណូលថវិកាជាតិជាមធ្យមមានកំរិតទាប (៧១%) ដែលទន្ទឹមនឹងនោះ ការអនុវត្តចំណូលចរន្តជាមធ្យមបានរហូតដល់ ៩៧%។ ចំណូលមូលធនដែលបង្ហាញក្នុងតារាងវិភាគនេះជាតួលេខដែលឆ្លងកាត់រតនាគារជាតិតែប៉ុណ្ណោះ។ មានតួលេខចំណូលមូលធនផ្សេងទៀតដែលឆ្លងត្រង់ទៅក្រសួង–ស្ថាប័នសាមីសម្រាប់ការអនុវត្តគំរោង។ សមាមាត្រតូចដូច្នេះ នៃការអនុវត្តគំរោងចំណូលមូលធនក្នុងតារាងវិភាគ ដោយសារមូលហេតុ ក.ស.វ. មិនមានតួលេខទាំងនោះ។

- *បើធៀបនឹងខែមុន **ចំណាយថវិកាជាតិកើនឡើង** ១៩% និងកើនឡើង ៥១% ក្នុងរយៈពេល១២ខែ។* ការកើនឡើងចំណាយថវិកាជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណាយចរន្ត*កើនឡើង ៣៤%* ។ ចំណែកឯចំណាយមូលធន*ថយចុះ២១%* បើធៀបនឹងខែមុន ប៉ុន្តែ*កើនឡើង ៧៣% ក្នុងរយៈពេល១២ខែ។*
- ***តុល្យភាពថវិកាជាតិក្នុងខែវិច្ឆិកានេះមានអតិរេកចំនួន ៩៣ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុ

- ក្នុងខែវិច្ឆិកាឆ្នាំ ២០១០ **រូបិយវត្ថុ** $M_2$ មានចំនួន ***១៩,១០៨ពាន់លានរៀល*** ថយចុះ១.៣% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ២៣% ក្នុង រយៈពេល១២ខែ។ ការថយចុះនៃ $M_2$ នាខែនេះបណ្តាលមកពី ប្រាក់បញ្ញើចរន្ត ថយចុះ ០.៤% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ថយចុះ ១.៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ថយចុះ ១.៧% ។ គួរចាប់អារម្មណ៍ថា រូបិយវត្ថុក្រៅធនាគារនៅខែនេះកើនឡើង ០.៨% ធៀបនឹងខែមុន ។
- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** នាខែវិច្ឆិកាឆ្នាំ ២០១០នេះ មានចំនួន**២,៤៦៧ លានដុល្លារ** *កើនឡើង ០.៣%* ធៀបនឹងខែមុន និងកើនឡើង ៧.៧% ក្នុងរយៈពេល១២ខែ។
- ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលក្នុងខែវិច្ឆិកាឆ្នាំ ២០១០ មានចំនួន **២,២០០ពាន់លានរៀល** ក្នុងនោះ ឥណទេយ្យចំពោះរាជរដ្ឋាភិបាល **២៧០ពាន់លានរៀល** និងប្រាក់បញ្ញើរាជរដ្ឋាភិបាល **២,៤៧០ ពាន់លានរៀល**។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែវិច្ឆិកាឆ្នាំ ២០១០នេះ មានចំនួន **៧,៤៨៤ ពាន់លានរៀល** កើនឡើង ១.៣% បើធៀបនឹងខែមុន និងកើនឡើង ២៦% ក្នុងរយៈពេល ១២ខែ។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជជារួមមានការកើនឡើងជាលំដាប់*** ដោយឡែកក្នុងខែវិច្ឆិកានេះមានចំនួន ១២,៦១៤ ពាន់លានរៀល ថយចុះ ០.៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៤% ក្នុងរយៈពេល១២ខែ។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ក្នុងខែវិច្ឆិកាឆ្នាំ ២០១០នេះ មានចំនួន **១,៧២០ ពាន់លានរៀល** កើនឡើង ០.៩% បើធៀបនឹងខែមុន និងកើនឡើង ៤១% ក្នុងរយៈពេល១២ខែ
- អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យមនៃធនាគារពាណិជ្ជទាំងអស់) ក្នុងខែវិច្ឆិកានេះស្មើនឹង ៦.៥៨% ថយចុះ ០.២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១.៧% ក្នុង រយៈពេល១២ខែ។
- អត្រាការប្រាក់បញ្ញើប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង **៤.៤%** កើនឡើង ០.២% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១៩% ក្នុងរយៈពេល១២ខែ។
- អត្រាការប្រាក់កំចីប្រចាំឆ្នាំជារៀលនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង ២២.៩៧% កើនឡើង ០.៧% ធៀបនឹងខែមុន និងកើនឡើង ០.៩% ក្នុង រយៈពេល១២ខែ។
- អត្រាការប្រាក់កំចីប្រចាំឆ្នាំជាដុល្លារនៅធនាគារពាណិជ្ជ (អត្រាមធ្យម) ស្មើនឹង ១៧.១២% កើនឡើង ៦.៣% ធៀបនឹងខែមុន និងកើនឡើង ៤.១% ក្នុង រយៈពេល១២ខែ។

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

- កសិកម្ម
  - ផលិតកម្មនេសាទ: មិនមានតួលេខ
- ឧស្សាហកម្ម
  - ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១,០៣៣ពាន់លានរៀល (បានពី២០៧រោងចក្រ)។
  - ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១៨៤.៧លានគីឡូវ៉ាត់ម៉ោង កើនឡើង ០.៩% បើធៀបនឹងខែមុន និងកើនឡើង ១៨% ក្នុងរយៈពេល១២ខែ។

– អគ្គិសនីផ្គត់ផ្គង់ដោយរ៉ាអគ្គិសនីមានចំនួន ១៨៤.៧លានគីឡូវ៉ាត់ម៉ោង ថយចុះ ២៧% បើធៀបនឹង ខែមុន និងថយចុះ ១០% ក្នុងរយៈពេល១២ខែ។

➢ **សំណង់**

- **សំណង់អនុញ្ញាតឲ្យសាងសង់:** មិនមានតួលេខ

➢ **វិនិយោគ៖** នាខែវិច្ឆិកានេះគម្រោងវិនិយោគអនុញ្ញាតិដោយ គ.វ.ក. មានចំនួន ៨។ បើគិតជា ទុនវិនិយោគ មានទឹកប្រាក់ស្មើនឹង **១០១២.៧លានដុល្លារ** កើនឡើង ២៨៥០% បើធៀបនឹងខែមុន និងកើនឡើង ៧០១៣% ក្នុងរយៈពេល ១២ខែ។ តាមរយៈគម្រោងទាំងនេះ អាចបង្កើតការងារបាន **១៥.៦៣ន់នាក់**។

➢ **សេវាកម្ម និងទេសចរណ៍**

- **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម**នៅក្រសួងពាណិជ្ជកម្ម: មិនមានតួលេខ
- **ក្រុមហ៊ុនដែលបានចុះបង់ពន្ធដារតាមរបបពិត:** មិនមានតួលេខ
- **ការដាក់ពាក្យរកការងារទៅក្រៅប្រទេសនៅក្រសួងការងារ:** មិនមានតួលេខ
- អ្នកទទួលបានការងារក្រៅប្រទេស: មិនមានតួលេខ
- **ទំនិញឆ្លងកាត់តាមផែ** (សរុប៦ផែ) មានចំនួន ៣០៩.៦ ពាន់តោន ថយចុះ ២.៥% បើធៀបនឹងខែមុន និង ថយចុះ ២៤% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ៖

– ទំនិញឆ្លងកាត់ផែកំពង់សោមថយចុះ ១៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥.៧% ក្នុងរយៈពេល១២ខែ

– ទំនិញឆ្លងកាត់ផែឧកញ៉ាម៉ុងថយចុះ ៥៧% បើធៀបនឹងខែមុន និងថយចុះ ៦៤% ក្នុងរយៈពេល១២ខែ

– ទំនិញឆ្លងកាត់ផែស្រែអំបិល និងកោះកុងកើនឡើង ៥៣៤% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ៧៧% ក្នុងរយៈពេល១២ខែ

–ទំនិញឆ្លងកាត់ផែភ្នំពេញកើនឡើង ៦% បើធៀបនឹងខែមុននិងកើនឡើង ២៥% ក្នុងរយៈពេល១២ខែ

- **អ្នកដំណើរតាមផ្លូវអាកាស** (អន្តរជាតិ) មានចំនួន ៣១៧ពាន់នាក់ កើនឡើង ២៦% បើធៀបនឹងខែមុន និងកើនឡើង ៧៤% ក្នុង រយៈពេល១២ខែ។
- **ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស**មាន ៤៤ពាន់នាក់ ថយចុះ ១២% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៨% ក្នុងរយៈពេល១២ខែ។
- **ចំនួនអ្នកទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជា**មាន ២៥០ពាន់នាក់ កើនឡើង ២២% បើធៀបនឹងខែមុន និងកើនឡើង ២៨% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវអាកាសមាន១៣៩ពាន់នាក់ កើនឡើង ២៩% បើធៀបនឹងខែមុន និងកើនឡើង ៣២% ក្នុងរយៈពេល១២ខែ។

✓ អ្នកទេសចរតាមផ្លូវគោក និងទឹកមាន ១០៤ពាន់នាក់ កើនឡើង ៦.៤% បើធៀបនឹងខែមុន និងកើនឡើង ៣២% ក្នុងរយៈពេល១២ខែ។

- ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ (ទូទាំងប្រទេស) មានចំនួន៩,៧៦៧នាក់ កើនឡើង ១៣៦% បើធៀបនឹងខែមុន និងកើនឡើង ១១% ក្នុងរយៈពេល១២ខែ។

## ៥) ស្ថានភាពពាណិជ្ជកម្ម

➢យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែវិច្ឆិកា មានចំនួន ១,៦៨១ពាន់លានរៀល កើនឡើង ៧.៧% បើធៀបនឹងខែមុន និងកើនឡើង ២២% ក្នុងរយៈពេល១២ខែ។ ក្នុងនោះ៖

| ទំនិញដែលកើនឡើង (វិច្ឆិកា/តុលា) (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) | ទំនិញដែលថយចុះ (វិច្ឆិកា/តុលា) (ក្នុងវង់ក្រចក: បំរែបំរួលក្នុងរយៈពេល១២ខែ) |
|---|---|
| - ប្រេងឥន្ធនៈ +១.១% ( +៦.២%)<br>- ឧស្ម័នៈ +១០% ( +១៥%)<br>- ដែកសំណង់: +១៤% ( +១៤%)<br>- ស៊ីម៉ង់: +២៤% ( −១២%)<br>- គ្រឿងអេឡិចត្រូនិចៈ +៦៦% ( +១៩%)<br>- រថយន្តសរុប (ពាន់លានរៀល) +២៣% (+៤១%)<br>- ត្រាក់ទ័រនិងគោយន្ត: +១៨% ( +២៥៥%)<br>- ម៉ូតូៈ +១៩% ( +៣៧%)<br>- ផ្លែឈើនិងបន្លែ: +១៤% ( −៣៨%)<br>- ជីនិងថ្នាំកសិកម្ម: +៣% ( +៥៥%) | - ស្រូវសាលី: −២៦% ( −២១%)<br>- អង្ករ: −៥% ( −២៤%)<br>- បារីៈ −២៨% ( −៥៦%)<br>-នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ −១៧%( +៣៨%) |

➢**ការនាំចេញ** ក្នុងខែវិច្ឆិកាឆ្នាំ២០១០ មានចំនួន ១,២០១ពាន់លានរៀល ថយចុះ ២២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៦% ក្នុងរយៈពេល១២ខែ។ ក្នុងនោះការនាំចេញដែលថយចុះមាន ផលិតផលឈើកែច្នៃ ២២% ផលិតផលវាយនភណ្ឌ និងស្បែកជើង ២៤% អង្ករ ១៣% ផលិតផល នេសាទ ១៧% ។ ការនាំចេញដែលកើនឡើងមាន កៅស៊ូ ៣៧%។

➢ *ក្នុងខែវិច្ឆិកាឆ្នាំ២០១០នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាពចំនួន ៤៨០ពាន់លានរៀល ។*

## ៦. កំណត់សម្គាល់សំខាន់ៗ

### ៦.១. បញ្ហាសំខាន់ៗ នៃស្នូរតីអង្គប្រជុំ

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) អតិផរណា: នាខែវិច្ឆិកាឆ្នាំ២០១០នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខបើធៀបនឹងខែមុន មានការថយចុះក្នុងកំរិតយ៉ាងខ្ពស់ដែលមិនធ្លាប់មាន ក្នុងឆ្នាំ ២០១០នេះ។ ការនេះអនុញ្ញាតិឲ្យមានការសន្និដ្ឋានថា អត្រាអតិផរណាឆ្នាំ ២០១០ ប្រហែលជាមិនលើស៥%ឡើយ (បើគិត ១១ខែ អត្រាអតិផរណាឆ្នាំ ២០១០ ស្មើ ៤.១%)។

២) អត្រាការប្រាក់កំចីក្នុងសេដ្ឋកិច្ចកម្ពុជាមានកំរិតខ្ពស់ ដែលបង្ករការលំបាកដល់ការលូតលាស់សហគ្រាសធនតូច និងមធ្យម និងការអភិវឌ្ឍធុរកិច្ចជារួម។ ឥឡូវនេះគួរដល់ពេលដែលធនាគារជាតិ ធ្វើនិយតកម្មក្នុងទីផ្សាររូបិយវត្ថុ ដើម្បីបន្ទាបអត្រាការប្រាក់ជាបណ្តើរៗ។

## ៦.២. ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកា ឆ្នាំ២០១០នេះ សូចនាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | ធៀបនឹងខែមុន | ក្នុងរយៈពេល១២ខែ | ផ្សេងៗ |
|---|---|---|---|
| ១.ចំណូលពីអាកាសចរណ៍ស៊ីវិល | +៦៤% | –៨២% | |
| ២. ផលទុននៃសកម្មភាពទេសចរណ៍ | +៥១% | +២៧% | |
| ៣. ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | –៥៥% | –៨៣% | |
| ៤. ការលក់អចលនកម្ម | +៤២៣% | +១១៨៤០% | |
| ៥. ការនាំចូលរថយន្ត | +២៣% | +៤១% | |
| ៦. ការនាំចេញផលិតផលឈើកែច្នៃ | –២២% | +៦២៣% | |
| ៧. ការនាំចេញអង្ករ | –១៣% | +៩៥% | |




កំណត់សំគាល់

- ព័ត៌មាន និងទិន្នន័យពណ៌ បៃតង សំដៅលទ្ធផលល្អ
- ព័ត៌មាន និងទិន្នន័យពណ៌ ក្រហម សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង

# សកម្មភាពដ៏ទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១២/១០<br>ម៉ោង ១៦ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសសមាជិកភាពពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ជូនឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសនៃរាជបណ្ឌិតសភាកម្ពុជា និងពិធីប្រគល់សញ្ញាបត្រកិត្តិយសបណ្ឌិត នៃរាជបណ្ឌិតសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ។ |
| ២ | ០២/១២/១០<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមក្នុងពិធីបើកមហាសន្និបាតលើកទី៦ របស់ ICAPP ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី ។ |
| ៣ | ០២/១២/១០<br>ម៉ោង ១៨ : ៣០នាទី | ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីលៀងសាយភោជន៍ អបអរសាទរមហាសន្និបាតលើកទី៦ និងខួបអនុស្សាវរីយ៍លើកទី១០ នៃការបង្កើតសន្និសីទអន្តរជាតិនៃគណបក្សនយោបាយនៅអាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅកោះពេជ្រ។ |
| ៤ | ០៦/១២/១០<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រ គ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+១) ជំនាន់ទី១៤, ទី១៥ និងគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី១១, ទី១២ ជូនដល់គរុនិស្សិត និងគរុសិស្ស នៃវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៥ | ០៦/១២/១០<br>ម៉ោង ១១ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើសេចក្ដីព្រាង៖<br>១- អនុក្រឹត្យ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។<br>២- សំណើសុំបញ្ចូលគម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្មអនុភាពតម្លើង ២៧០ មេហ្គាវ៉ាត់ ជំហានទី១ នៃផែនការអភិវឌ្ឍន៍រោងចក្រអគ្គិសនីធ្យូងថ្មកម្លាំង ៧០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ(ដើម្បីដាក់ចូលក្នុងរបៀបវារៈប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១០)<br>ដើម្បីត្រៀមប្រជុំ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ០៦/១២/១០<br>ម៉ោង ១៥ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយក្រុមប្រឹក្សាភិបាលសិប្បករអង្គរ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៧/១២/១០<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យលើសេចក្តីព្រាង៖<br>១- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។<br>២- សំណើសុំបញ្ចូលគម្រោងវិនិយោគសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្មអនុភាពតម្លើង ២៧០ មេហ្គាវ៉ាត់ ជំហានទី១ នៃផែនការអភិវឌ្ឍន៍រោងចក្រអគ្គិសនីធ្យូងថ្មកម្លាំង ៧០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ(ដើម្បីដាក់ចូលក្នុងរបៀបវារៈប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១០)<br>៣- អនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។<br>៤១- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ។<br>៤២- អនុក្រឹត្យ ស្តីពីរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។<br>៤៣-អនុក្រឹត្យ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។<br>៥- បញ្ហាផ្សេងៗ |
| ៨ | ១៤/១២/១០<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យលើ៖<br>១- សេចក្តីព្រាង ច្បាប់ស្តីពីលក្ខន្តិកៈ នៃអាជ្ញាសាលា។<br>២- សេចក្តីព្រាង អនុក្រឹត្យស្តីពីផលិតកម្មកសិកម្ម តាមកិច្ចសន្យា។<br>៣- បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៥/១២/១០<br>ពេញមួយថ្ងៃ | ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលអាទីហ្សង់អង្គរ នៅរាជធានីភ្នំពេញ។ |
| ១០ | ១៧/១២/១០<br>ម៉ោង ១១ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មាតុភូមិនិវត្តន៍ជាផ្លូវការនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១១ | ១៧/១២/១០<br>ម៉ោង ១៧ : ០០ នាទី | ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈវិស្វករកម្ពុជា និងស្ថាប័នវិស្វករម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១២ | ២០/១២/១០<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូនវកាយរឹទ្ធិ ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា និងលោកជំទាវ នៅក្នុងបរិវេណខាងមុខប្រសាទបាយ័ន ខេត្តសៀមរាប។ |
| ១៣ | ២១/១២/១០<br>ម៉ោង ០៨ : ៣០<br>នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់-ទទួល សម្ភារៈដែលជាអំណោយរបស់សាធារណៈរដ្ឋកូរ៉េ ជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិភេរវកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅមូលដ្ឋានកងទ័ពអាកាស (ពោធិចិនតុង)។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ២១/១២/១០<br>ម៉ោង ១៦ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនលោក Takuya OKADA ប្រធានមូលនិធិអូកាដា ជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៥ | ២១/១២/១០<br>ម៉ោង ១៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី នៅ Raffles le Royal។ |
| ១៦ | ២២/១២/១០<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ១៧ | ២៣/១២/១០<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមប្រជុំការងារគម្រោងសាងសង់អគារទីស្នាក់ការអាជ្ញាធរអប្សរាខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | ២៣/១២/១០<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យអតីតអភិបាលរងខេត្តយូណាន់ នៃសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងសវនាការ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | ២៤/១២/១០<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។<br>២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។<br>៣- សេចក្តីព្រាងអនុក្រឹត្យចំនួន០៣របស់អង្គភាពប្រឆាំងអំពើពុករលួយ :<br>៣-១. សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ។<br>៣-២. សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងនិងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។<br>៣-៣. សេចក្តីព្រាងអនុក្រឹត្យ ស្តីពីរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។<br>៤-បញ្ហាផ្សេងៗ |
| ២០ | ២៩/១២/១០<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធ និងបើកការដ្ឋានសាងសង់ស្ពានអាកាសស្តុបពេទ្យលោកសង្ឃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នៅរាជធានីភ្នំពេញ ។ |
| ២១ | ២៩/១២/១០<br>ម៉ោង ១៤ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ២២ | ៣០/១២/១០<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ៣០/១២/១០<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃ និងត្រួតពិនិត្យការសាងសង់អគារលក់សំបុត្រពេលថ្ងៃ នៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរណ៍ខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ៣១/១២/១០<br>ម៉ោង ០៩ : ៣០ នាទី | ដឹកនាំបើកកិច្ចប្រជុំជាមួយឯកឧត្តម ឯកអគ្គរដ្ឋទូត នៃសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម គីម សយសាម៉ាឡែន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៧/១២/១០ | ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ ក្រោមអធិបតីភាព ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរងទី១ រាជរដ្ឋាភិបាល ដើម្បីពិភាក្សាលើសេចក្តីសម្រេចស្តីពី សមាសភាព និងភារកិច្ច ក្រសួងស្ថាប័នស្ថិតក្រោមសមត្ថកិច្ចក្រុមប្រឹក្សាសហគមន៍អាស៊ានទាំងបីរបស់កម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៧/១២/១០ | ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង គណៈវិស្វករកម្ពុជា និងស្ថានប័នវិស្វករម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២១/១២/១០ | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនលោក Takuya OKADA ប្រធានមូលនិធិអូកាដាជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលសន
## អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំធ្នូ ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៥/១២/១០ | ជួបប្រជុំពិភាក្សាការងារជាមួយ Mr. Nicolas Deviller និង Mr. Gardère អំពីអាទីហ្សង់អង្គរ នៅរាជធានីភ្នំពេញ។ |
| ២ | ១៧/១២/១០ | ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង គណៈវិស្វករកម្ពុជា និងស្ថាប័នវិស្វករម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ២១/១២/១០ | ចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនលោក Takuya OKADA ប្រធានមូលនិធិអូកាដាជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពដទៃទៀតរបស់ សមាជិក-សមាជិកា
## នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១០

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ៨/១២/១០ | ឯកឧត្តម **ម៉ម សារិទ្ធ** ចូលរួមក្នុងកិច្ចប្រជុំផ្ទៃក្នុងជាមួយក្រុមការងារតាក់តែងច្បាប់ឧបាស្រ័យពាណិជ្ជកម្មកម្ពុជា នៅសណ្ឋាគារហ៊ីវ៉ាម៉ារី។ |
| ២ | ០៩/១២/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្ដីព្រាងរបាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែវិច្ឆិកា របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |
| ៣ | ១៤/១២/១០ | ឯកឧត្តម **ឡុង ឈាង** ចូលរួមប្រជុំពិភាក្សាស្វែងយល់ពីសេដ្ឋកិច្ចវិស័យជលផល នៅរដ្ឋបាលជលផល ដឹកនាំប្រតិភូអនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន**។ |
| ៤ | ១៦-១៧/១២/១០ | ឯកឧត្តម **ម៉ម សារិទ្ធ** ចូលរួមក្នុងកិច្ចប្រជុំជាមួយជំនាញការ USAID នៅសណ្ឋាគារខ្សាច់មាស ខេត្តព្រះសីហនុ។ |




រូបភាពក្នុងកិច្ចប្រជុំ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## របាយការណ៍សង្ខេបស្តីពី

# កិច្ចប្រជុំនៅរដ្ឋបាលជលផល



កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១០:០០ នាទីព្រឹក ឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន** ទីប្រឹក្សាអមគណៈរដ្ឋមន្ត្រី សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានអនុក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម បានដឹកនាំអនុក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម ទៅចូលរួមប្រជុំនៅរដ្ឋបាលជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្វែងយល់ និងសិក្សាស្រាវជ្រាវពីសេដ្ឋកិច្ចជលផល។ នៅក្នុងឱកាសនោះ ឯកឧត្តម **សម នៅ** អនុប្រធានរដ្ឋបាលជលផល និងជាតំណាងឯកឧត្តម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល និងលោកប្រធាននាយកដ្ឋាន និងប្រធានវិទ្យាស្ថានទាំងអស់ បានចូលរួមក្នុងកិច្ចប្រជុំបានស្វាគមន៍ និងបានធ្វើបទបង្ហាញពីសភាពការណ៍នៃវិស័យជលផលកន្លងមក និងទិសដៅខាងមុខ ជូនអង្គប្រជុំជ្រាប។ បន្ទាប់មកឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន** ឯកឧត្តម អនុប្រធានអនុក្រុម និងសមាជិក អនុក្រុមសិក្សាស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម បានលើកជាសំនួរចាប់អារម្មណ៍ចំណុចខ្លះៗមានជាអាទិ គឺសំនួរពាក់ព័ន្ធទៅនឹងផលប៉ះពាល់ នឹងវិស័យជលផលដូចជាការធ្វើទំនប់វារីអគ្គីសនី ការកាប់ឆ្ការរានព្រៃលិចទឹក ការប្រើឧបករណ៍ធក់ត្រីជាដើម។

ទីបញ្ចប់ ឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន** បានថ្លែងអំណរគុណដល់ឯកឧត្តម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកប្រធានរដ្ឋបាលជលផល និងថ្នាក់ដឹកនាំរដ្ឋបាលជលផលទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ប្រកបដោយសាមគ្គីភាព និងភាពស្និទ្ធស្នាល ៕





# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម [illegible] | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការ ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | ឯកឧត្តម [illegible] | សមាជិកបម្រុង ក.ស.វ. |
| និពន្ធឆ្លួច ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការរង ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក [illegible] | ប្រធានការិយាល័យ ក.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក [illegible] | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in